**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ

## និង

## ការធ្វើលទ្ធកម្មពីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ លើផ្ទៃដីស្ថិតនៅ សង្កាត់ព្រែកតាសេក សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

## និង

## ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩១០ /៧៦៣ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការកំណត់ព្រំប្រទល់រដ្ឋបាល រវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការធ្វើអនុបយោគ
- តាមការសម្រេចជាគោលការណ៍ របស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១១ លើលិខិតលេខ ០១៨ ដនស / អវទ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១១ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- តាមសំណើ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១ :-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ៥២៩,១០ ហិកតា ( ប្រាំរយម្ភៃប្រាំបួនហិកតា និងមួយពាន់ម៉ែត្រក្រឡា)ស្ថិតនៅសង្កាត់ព្រែកតាសេក សង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងឃុំសំបួរ

មាស ស្រុកមុខកំពូល ខេត្តកណ្ដាល ដូចមានកំណត់ក្នុងនិយាមកា និង ប្លង់ទីតាំង ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ របស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ផ្ដុំជាមួយផ្ទៃដីទំហំ ៨០០ ហិកតា ( ប្រាំបីរយហិកតា) ដែលបានធ្វើអនុបយោគរួច តាមអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៨ ។ ទំហំដីសរុបមាន ១.៣២៩,១០ ហិកតា (មួយពាន់បីរយម្ភៃប្រាំបួនហិកតា និងមួយពាន់ម៉ែត្រក្រឡា)។

**មាត្រា ២ :-**

ទំហំដីសរុបដូចមានចែងក្នុងមាត្រា ១ ត្រូវបានចាត់ចែង ៖

-ត្រូវបានធ្វើលទ្ធកម្មពីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីដែលមានទំហំ ១.២៩២,៩០ (មួយពាន់ពីរយកៅសិបពីរហិកតា និងប្រាំបួនពាន់ម៉ែត្រក្រឡា)ដោយផ្ដល់ឱ្យក្រុមហ៊ុន**អិល.ថ៉ាយ.គី គ្រុប** កាន់កាប់ជាម្ចាស់កម្មសិទ្ធិ និងធ្វើការអភិវឌ្ឍន៍ ទៅតាមគម្រោងវិនិយោគរបស់ក្រុមហ៊ុន ។

-ត្រូវបានផ្ដល់ឱ្យក្រុមហ៊ុន **អិល.ថ៉ាយ.គី គ្រុប** នូវផ្ទៃដីផ្លូវដែលមានទទឹង៥០ ម៉ែត្រ បណ្ដោយប្រវែង ៧.៣២៨ ម៉ែត្រ និងមានទំហំប្រមាណ ៣៦,២០ហិកតា (សាមសិបប្រាំមួយហិកតា និងពីរពាន់ម៉ែត្រក្រឡា)កាន់កាប់ ប្រើប្រាស់តាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា សាងសង់ អាជីវកម្ម ផ្ទេរ( BOT )។

**មាត្រា ៣ :-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ អភិបាលខេត្តកណ្ដាល និងក្រុមហ៊ុន **អិល.ថ៉ាយ.គី គ្រុប** ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ